ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៦ លេខ ១ | មករា - មីនា ឆ្នាំ២០១២ | តម្លៃ ១.៥០០៛

# កម្ពុជា ឆ្នាំ២០១២៖ និន្នាការសំខាន់ៗ និងអាទិភាពគោលនយោបាយ ស្រង់ពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា[១]

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា លើកទី៦ បានប្រារព្ធឡើងកាលពីថ្ងៃទី ១៦ កុម្ភៈ ២០១២ នៅរាជធានីភ្នំពេញ ក្រោមកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal។ តំណាងជាន់ខ្ពស់មកពីខាងរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សហគមន៍ស្រាវជ្រាវ និងសង្គមស៊ីវិល បានមកជួបជុំគ្នាពិភាក្សាពី "អាទិភាពប្រទេសកម្ពុជា ដើម្បីលើកកម្ពស់កំណើនសម្រាប់គ្រប់គ្នា សមាហរណកម្មក្នុងតំបន់ និងការដឹកនាំអាស៊ាន"។ ក្នុងពេលថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកត់សម្គាល់ពីពេលវេលាដ៏ល្អប្រសើរនៃសន្និសីទនេះ គឺមុនពេលកម្ពុជា ទទួលវេណធ្វើជាប្រធានអាស៊ាន ហើយសម្តេច បានគូសបញ្ជាក់ពីតួនាទីសំខាន់នៃសន្និសីទនេះ ក្នុងការផ្តល់គំនិតពីអាទិភាពគោលនយោបាយនានាសម្រាប់ឆ្នាំខាងមុខ។ អត្ថបទនេះ ផ្តល់ទស្សនៈរួមមួយពីបញ្ហាសំខាន់ៗដែលបានលើកឡើងក្នុងវគ្គនីមួយៗ ដោយកំណត់ពីវិស័យដែលរដ្ឋាភិបាល គួរផ្តោតសកម្មភាពលើសម្រាប់ឆ្នាំ២០១២។ បទបង្ហាញនៅក្នុងសន្និសីទ អាចរកបាននៅលើគេហទំព័រ www.cdri.org.kh។



*សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថាគន្លឹះ ក្នុងពេលបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១២។*

ឆ្នាំ២០១២ អាចមានផ្លែផ្កាច្រើនជាងគេសម្រាប់កម្ពុជា បើធៀបនឹងប៉ុន្មានឆ្នាំកន្លងមកនេះ។ នៅឆ្នាំ២០១១ ផសស កើនជិតដល់ ៧% ហើយអត្រានេះ រំពឹងថានឹងអាចរក្សាបានក្នុងឆ្នាំ២០១២។ វិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ ដែលជាវិស័យជំរុញកំណើនសំខាន់ៗក្នុងសេដ្ឋកិច្ច កំពុងមានដំណើរការល្អ ហើយវិស័យសំណង់ហាក់ប្រែប្រួលប្រសើរឡើងវិញហើយ បន្ទាប់ពីរងការប៉ះទង្គិចធ្ងន់ធ្ងរក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុសាកល។ នៅឆ្នាំនេះដែរ កម្ពុជាទទួលវេណធ្វើជាប្រធានអាស៊ាន ដែលជាឱកាសសម្រាប់ការរៀបចំ និងពង្រឹងស្ថាប័នក្នុងតំបន់ដែលដ៏សំខាន់ និងកាន់តែមានឥទ្ធិពលខ្លាំងឡើងនេះ។

ក្នុងកាលៈទេសៈវិសេសនេះ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា បានវាយតម្លៃពីឱកាស និងបញ្ហាប្រឈម ចំពោះ

## មាតិកា

កម្ពុជា ឆ្នាំ២០១២៖ និន្នាការសំខាន់ៗ និងអាទិភាពគោលនយោបាយស្រង់ពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ......... ១
ភាពមិនស៊ីគ្នារវាងតម្រូវការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក៖ លទ្ធផលពីសិក្ខាសាលាផ្សព្វផ្សាយ ........ ៨
ការពិនិត្យពីសកម្មភាពផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា........................................ ១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........................ ១៤
— ស្ថានភាពក្នុងប្រទេស........................ ១៦
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......................................២៤

១ អត្ថបទនេះ ផ្អែកលើបទបង្ហាញនៅក្នុង សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១២ ដែលបានរៀបចំឡើងនៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ កុម្ភៈ ២០១២។ អត្ថបទ រៀបរៀងដោយលោក B. C. R. Flower ជានិស្សិតថ្នាក់បណ្ឌិតនៃសាកលវិទ្យាល័យ UCL និងជាកម្មសិក្សាការីផ្នែកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។ បទបង្ហាញក្នុងសន្និសីទ និងអត្ថបទសង្ខេបគោលនយោបាយនានា អាចរកបាននៅលើគេហទំព័រ www.cdri.org.kh។

គោលដៅរយៈពេលមធ្យមរបស់រដ្ឋាភិបាល ក្នុងការសម្រេចឲ្យបានឋានៈជាប្រទេសមានចំណូលថ្នាក់កណ្ដាល។ គោលដៅសំខាន់ គឺការកសាងពីលើមូលដ្ឋានគ្រឹះរឹងមាំ និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង និងមានចីរភាព។ សន្និសីទនេះ បានសង្កត់ធ្ងន់លើបីវិស័យជាប់ទាក់ទងគ្នាដែលត្រូវមានសកម្មភាពខាងគោលនយោបាយ ប្រសិនបើចង់សម្រេចគោលដៅខាងលើឲ្យបាន។ ទី១ គឺការប្រើប្រាស់ឱកាសល្អបានពីអាស៊ាន និងបណ្ដាញផ្សេងទៀតក្នុងតំបន់ ដើម្បីជំរុញពិពិធកម្ម ប្រសិទ្ធភាព និងកំណើនសេដ្ឋកិច្ច។ ទី២ គឺការលើកកម្ពស់តួនាទីរបស់វិស័យឯកជនឲ្យបានប្រសើរបំផុត ក្នុងបរិបទនៃសមាហរណកម្មក្នុងតំបន់ ដើម្បីជួយបង្កើនពិពិធកម្ម ប្រសិទ្ធភាព និងកំណើនសេដ្ឋកិច្ច។ ទី៣ គឺការរីកចម្រើនសម្រាប់គ្រប់គ្នា ដើម្បីឲ្យកម្ពុជា អាចផ្ទេរអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ចទៅដល់គ្រប់ស្រទាប់ប្រជាជន និងតំបន់ជាយៗ។

អត្ថបទសង្ខេបនេះ បង្ហាញពីនិន្នាការ និងអាទិភាពគោលនយោបាយនានា ដែលជាប់ពាក់ព័ន្ធនឹងខ្លឹមសារទាំងបីខាងលើ ព្រមទាំងសកម្មភាពផ្នែកគោលនយោបាយ គួរអនុវត្តនៅចំពោះមុខបញ្ហាស្នូល ដែលចោទក្នុងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍកម្ពុជា និងដែលបានគូសបញ្ជាក់ម្ដងហើយម្ដងទៀត នៅក្នុងសន្និសីទពោលគឺ សមត្ថភាពស្ថាប័នក្នុងការអនុវត្ត និងពង្រឹងគោលនយោបាយ។

## ការជំរុញសមាហរណកម្មក្នុងតំបន់

កម្ពុជា ត្រូវតែសម្របខ្លួនតាមការផ្លាស់ប្ដូរក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចពិភពលោក ដើម្បីអាចរីកចម្រើនឡើង។ ជាគោលការណ៍ កម្ពុជា ត្រូវធ្វើពិពិធកម្មចេញពីវិស័យនាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលជាកម្លាំងជំរុញកំណើនចម្បងកន្លងមក ទៅបង្កើតឧស្សាហកម្មថ្មីៗបន្ថែម ដើម្បីបំពេញតាមតម្រូវការទីផ្សារដទៃទៀត។ ក្នុងការងារនេះ ប៉ូលកំណើននៅតំបន់អាស៊ី អាចផ្ដល់ប្រភពថ្មីៗនៃតម្រូវការនូវផលិតផលកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ដោយឡែក លំនាំនាំចូលរបស់ប្រទេសចិនដែលមាន តម្រូវការធំធេងនូវផលិតផលអន្តរការី និងផលិតផលកសិកម្មនោះ គួរតែយកមកគិតគូរជាសំខាន់ក្នុងការកសាងយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់កម្ពុជា។ ការបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់ ជាចំណុចសំខាន់មួយនៃយុទ្ធសាស្ត្ររបស់កម្ពុជា ដើម្បីទាញយកអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លានៅតំបន់អាស៊ី។ សមាហរណកម្មស៊ីជម្រៅជួយកាត់បន្ថយ គម្លាតរវាងផលិតករនិងទីផ្សារ បន្ទុកចំណាយរបស់ផលិតករកម្ពុជា ដើម្បីចូលទៅក្នុងទីផ្សារអាស៊ាន ក៏ដូចជាបន្ទុកចំណាយរបស់ផលិតករអាស៊ាន ដើម្បីចូលទៅក្នុងទីផ្សារពិភពលោក។ ក្នុងកិច្ចប្រឹងប្រែងនេះ កម្ពុជាក្នុងឋានៈជាប្រធានអាស៊ាន មានស្ថានភាពល្អដើម្បីពង្រឹងសហប្រតិបត្តិការក្នុងតំបន់ និងសម្រេចឲ្យបាននូវ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) រួមគ្នាមួយ នៅឆ្នាំ២០១៥។ រដ្ឋាភិបាលកម្ពុជា បានលុបរួចហើយនូវពន្ធនាំចូលលើមុខទំនិញជាង ៩៨% ដែលមានប្រភពនៅអាស៊ាន។ នីតិវិធីឆ្លងកាត់ព្រំដែនដ៏ស្មុគស្មាញ និងគ្មានប្រសិទ្ធភាពក៏តម្រឹមគ្នាឡើងវិញ តាមការបង្កើតសេវាគយច្រកចេញចូលអាស៊ានតែមួយ (ASW)។ កម្ពុជានឹងចាប់ផ្ដើមសេវាច្រកចេញចូលតែមួយថ្នាក់ជាតិ (NSWs) នៅត្រីមាសទី៤ ឆ្នាំ២០១២ ដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការចូលរួមក្នុង ASW។

កត្តាគន្លឹះ សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាពេលអនាគត គឺមូលធនពីបរទេស ដូច្នេះរដ្ឋាភិបាលគួររៀបចំក្របខ័ណ្ឌច្បាប់ និងស្ថាប័នឲ្យងាយស្រួលទទួលយកមូលធនទាំងនោះ។ កិច្ចព្រមព្រៀងវិនិយោគគ្រប់ជ្រុងជ្រោយអាស៊ាន (ACIA) ដែលចាប់អនុវត្តនៅឆ្នាំនេះ ត្រូវគ្របដណ្ដប់លើសេរីភាវូបនីយកម្ម ការជំរុញនិងការពារវិនិយោគរបស់វិនិយោគិនក្នុងអាស៊ាន និងវិនិយោគិនបរទេសដែលមានមូលដ្ឋានក្នុងអាស៊ាន។ ការបំបាត់កំហិតលើវិនិយោគ នឹងទាក់ទាញវិនិយោគទុនកាន់តែច្រើន ហើយការការពារកាន់តែប្រសើរ និងនីតិវិធីមានតម្លាភាព នឹងជំរុញវិនិយោគទុនរយៈពេលវែងលើសកម្មភាពច្រើនបែបយ៉ាង។ ក្នុងរយៈពេលមធ្យម វិធានការនេះនឹងជំរុញការប្រកួតប្រជែងតាមវិស័យនានា ព្រមទាំងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

កំណែទម្រង់គោលនយោបាយនានា មានបំពេញបន្ថែមរួចហើយ ដោយគំនិតផ្ដួចផ្ដើមជាច្រើន ដើម្បីជំនះរបាំងរូបវ័ន្តផ្សេងៗរវាងប្រជាជាតិអាស៊ាននានា តាមការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹង។ គម្រោងហេដ្ឋារចនាសម្ព័ន្ធ វាជួយពង្រីកផលិតភាពក្នុងគ្រប់វិស័យ តាមរយៈការកាត់បន្ថយបន្ទុកចំណាយធ្វើអាជីវកម្ម និងជាឧបករណ៍សំខាន់មួយសម្រាប់ទាញយកសក្ដានុពលបង្កប់ក្នុងវិស័យកសិកម្មមកប្រើប្រាស់ តាមការបើកទ្វារឲ្យកសិដ្ឋានតូចៗចូលទៅដល់ទីផ្សារក្នុងតំបន់ និងក្នុងពិភពលោក និងទទួលបានបច្ចេកវិទ្យា សេវាកម្ម និងការវិនិយោគ។ គម្រោងច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ADB-GMS ជួយឲ្យមានការកែលំអបណ្ដាញផ្លូវថ្នល់ និងផ្លូវដែក រវាងកម្ពុជា និងមណ្ឌលផលិតកម្មនានាក្នុងតំបន់ កិច្ចសហប្រតិបត្តិការផ្នែកអគ្គិសនីឆ្លងកាត់ព្រំដែន និងការបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធ ICT និងទូរគមនាគមន៍ក្នុងតំបន់។ គម្រោងឈានមុខគេ គឺការស្ដារជួសជុលបណ្ដាញផ្លូវដែកនៅកម្ពុជា ដែលគ្រោងចប់សព្វគ្រប់នៅឆ្នាំ២០១៣ ដោយមានផ្លូវដែកមេមួយខ្សែដំណើរការបានពេញលេញភ្ជាប់ពីក្រុង Kunming ទៅសិង្ហបុរី។

អាស៊ានដ៏រឹងមាំ ផ្ដល់ឲ្យកម្ពុជានូវវេទិកាមានប្រសិទ្ធភាពខ្ពស់សម្រាប់ការចូលរួមក្នុងទីផ្សារនៅអាស៊ី និងនៅតាមតំបន់ដទៃទៀត ដែលបង្កើតជាប្រភពតម្រូវការថ្មីៗសម្រាប់ផលិតផលនានា។ កន្លងមកមានកិច្ចព្រមព្រៀងមួយចំនួនហើយ សម្រាប់ជួយសម្រួលឲ្យមានទំនាក់ទំនងសេដ្ឋកិច្ចកាន់តែច្រើន រវាងបណ្ដាប្រទេសសមាជិកអាស៊ាន និងជាមួយប្រទេសសំខាន់ៗដទៃទៀតនៅលើពិភពលោក។ អាស៊ាន បានចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ជាច្រើនដែលអាចជួយលើកកម្ពស់

រូបភាព ១៖ ការកែលំអហេដ្ឋារចនាសម្ព័ន្ធនៅតំបន់អាស៊ាន




*ប្រភព៖ បទបង្ហាញរបស់ ឯ.ឧ. ហង់ ជួន ណារ៉ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី ១៦ កុម្ភៈ ២០១២។*

លទ្ធភាពនាំចេញរបស់ប្រទេសជាសមាជិក ទៅកាន់ប្រទេសចិន កូរ៉េ អូស្ត្រាលី និងញូវហ្សេឡែន។

ការរួបរួមគ្នា និងភាពចុះសម្រុងក្នុងចំណោមសមាជិក គឺជាមូលដ្ឋានគ្រឹះសម្រាប់អាស៊ាន និងជាគន្លឹះដើម្បីសម្រេចបានប្រសិទ្ធភាពខ្ពស់នៅពេលអនាគត។ ដូច្នេះ គួរប្រឹងប្រែងកាន់តែខ្លាំងទៀត ដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងអាស៊ាន និងប្រទេសមានកម្រិតលូតលាស់ទាបជាង ដូចជា កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក។ ដំណើរការនៃ វេទិកាតំបន់អាស៊ាន អាស៊ាន+៣ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ផ្តល់ឱកាសដ៏ល្អសម្រាប់ជំរុញកិច្ចសហប្រតិបត្តិការ សន្តិភាព និងសន្តិសុខក្នុងតំបន់ ការបង្ការទំនាស់ ការដោះស្រាយភាពតានតឹង ក៏ដូចជាការគោរព និងការពារផលប្រយោជន៍របស់ប្រទេសទាំងតូចទាំងធំនៅក្នុងតំបន់។

## ការជំរុញវិស័យឯកជន

វិស័យឯកជន ជាកម្លាំងជំរុញការរីកចម្រើននៅកម្ពុជាក្នុងពេលកន្លងមក។ ការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចប្រទេសកម្ពុជានៅដើមទសវត្សរ៍១៩៩០ បានបើកផ្លូវឲ្យមានការធ្វើវិនិយោគយ៉ាងច្រើនផុសផុលលើវិស័យដីធ្លី សំណង់ និងរោងចក្រកាត់ដេរ។ ទោះបីក្របខ័ណ្ឌដ៏សាមញ្ញផ្នែកស្ថាប័ន និងច្បាប់ដែលបានដាក់ចេញក្នុងទសវត្សរ៍១៩៩០ បានផ្តល់ជាក្របខ័ណ្ឌសម្រាប់វិនិយោគឯកជនក្តី ប៉ុន្តែសមត្ថភាពមានកម្រិតក្នុងការពង្រឹងអនុវត្តច្បាប់ បានទុកឲ្យទីផ្សារនៅមានការយកប្រាក់កម្រៃក្រៅផ្លូវការជាច្រើន។ ដោយមូលហេតុនេះ ទោះបីកំណើនមានកម្រិតខ្ពស់ក្តី ក៏វាមានលក្ខណៈមិនស្មើគ្នា គ្មានស្ថិរភាព និងគ្មានសមធម៌ទេ។ ដើម្បីដោះស្រាយបញ្ហាខាងលើ រដ្ឋាភិបាលបានប្រឹងប្រែងកសាងក្នុងទសវត្សរ៍កន្លងមកនេះ នូវសមត្ថភាពស្ថាប័នដ៏ចាំបាច់ ដើម្បីជួយឲ្យវិនិយោគឯកជនអាចដំណើរការបានប្រកបដោយសុវត្ថិភាព តម្លាភាព និងមានច្បាប់ទម្លាប់ល្អ។

វិនិយោគផ្ទាល់ពីបរទេស បានស្ទុះឡើង ដោយការងារកសាងស្ថាប័នចំគោលដៅល្អទាំងនេះ បានផ្តល់ទំនុកចិត្តដល់វិនិយោគទាំងខ្នាតតូច និងខ្នាតធំ។ ទោះយ៉ាងនេះក្តី វិនិយោគភាគច្រើនបានធ្វើឡើងតែក្នុងឧស្សាហកម្មកាត់ដេរ និងសំណង់ប៉ុណ្ណោះ ហើយបទពិសោធន៍ពីវិបត្តិហិរញ្ញវត្ថុ បង្ហាញថា វិនិយោគប្រភេទនេះមិនសូវឋិតថេរ និងងាយរលាយបាត់ បើសិនលក្ខខណ្ឌផ្សេងៗប្រែប្រួល។ លំនាំវិនិយោគបែបនេះ វាផ្ទុយគ្នានឹងគោលដៅរបស់រដ្ឋាភិបាល ដែលចង់បានកំណើនមានស្ថិរភាព និងចីរភាព។ ដូច្នេះ ក្របខ័ណ្ឌគោលនយោបាយ ត្រូវតែសំដៅតម្រឹមឲ្យស៊ីគ្នានូវអាទិភាពនានា របស់វិស័យឯកជន និងរបស់រដ្ឋាភិបាល។

ការពង្រឹងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការវិស័យឯកជន-សាធារណៈ ជាគន្លឹះសម្រាប់បន្ស៊ីផែនការដែលមិនស្របគ្នា រវាងវិស័យសាធារណៈ និងឯកជន។ ជាពិសេស គោលនយោបាយ និងស្ថាប័ននានា គួរជំរុញភាពជាដៃគូរវាងវិស័យឯកជន-សាធារណៈ ដើម្បីឲ្យសកម្មភាពផ្នែកគោលនយោបាយ ឆ្លើយតបនឹងតម្រូវការចាំបាច់ផ្នែកសេដ្ឋកិច្ច ឬដើម្បីកៀរគរវិស័យឯកជន

ឲ្យបំពេញតាមចក្ខុវិស័យនៃសមាហរណកម្មក្នុងតំបន់ និងកំណើនសម្រាប់គ្រប់គ្នា មានចីរភាពល្អ និងសំបូរបែប។

កម្ពុជា ត្រូវធ្វើការជាមួយបណ្តាប្រទេសមានអំណាចក្នុងតំបន់ ដើម្បីបង្កើតបរិយាកាសផ្នែកបទបញ្ញត្តិ និងស្ថាប័នមួយ ដែលជួយឲ្យវិស័យឯកជនរីកដុះដាល នៅក្នុងយុគសម័យនៃកំណើនកិច្ចសហប្រតិបត្តិការក្នុងតំបន់។ ក្នុងនេះដែរ វិស័យឯកជន ត្រូវចេះប្រើប្រាស់ឱកាសល្អនៃកំណើនការតភ្ជាប់គ្នាក្នុងតំបន់ដែលកើតចេញពីអាស៊ានដ៏រឹងមាំ។ សម្រាប់កម្ពុជា អាស៊ានជួយសម្រួលដល់ការពង្រឹង និងពង្រីកបណ្តាញចែកចាយ និងផលិតកម្ម ដែលជាកត្តាជំរុញប្រសិទ្ធភាព លើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗ និងពង្រីកទីផ្សារសម្រាប់តួអង្គក្នុងវិស័យឯកជន។ បច្ចុប្បន្ន ប្រទេសមួយចំនួនក្នុងតំបន់ ដូចជា ម៉ាឡេស៊ី សិង្ហបុរី និងថៃ សម្រេចបាននូវក្រុមហ៊ុនពហុជាតិដែលអាចទាញយកអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ច និងសមាហរណកម្មក្នុងតំបន់អាស៊ាន។ ជាមួយនឹងគោលនយោបាយសមស្រប និងការប្តេជ្ញាចិត្ត កម្ពុជាសង្ឃឹមថានឹងអាចអនុវត្តបានដូចប្រទេសទាំងនោះដែរ។

ប្រសិនបើវិស័យឯកជនកម្ពុជា ចង់ចូលរួមក្នុងក្រុមអាជីវកម្មមានឋានៈខ្ពស់ក្នុងតំបន់អាស៊ាននោះ ពួកគេត្រូវយល់ដឹងឲ្យបានកាន់តែប្រសើរពីកម្លាំងប្រៀបធៀប និងកម្លាំងប្រកួតប្រជែងនៃសេដ្ឋកិច្ចខ្លួន ហើយចេះប្រើប្រាស់កម្លាំងទាំងនោះ។ ការស្រាវជ្រាវសំខាន់ខ្លាំងណាស់ ដើម្បីជំនះបញ្ហាកង្វះខាតព័ត៌មានដែលកាត់បន្ថយប្រសិទ្ធភាព គោលនយោបាយជំរុញវិស័យឯកជន។ បណ្តាញស្ថាប័នសិក្សាស្រាវជ្រាវនៅកម្ពុជា ក៏ត្រូវកៀរគរឲ្យជួយវាយតម្លៃពីឧបសគ្គនានាដែលរារាំងអាជីវកម្មកម្ពុជា ក្នុងការប្រើប្រាស់បណ្តាញសេដ្ឋកិច្ចក្នុងតំបន់ដែរ។ ការស្រាវជ្រាវត្រូវមានលក្ខណៈផ្តោតលើគោលនយោបាយ និងប្រើប្រាស់ក្របខ័ណ្ឌវិភាគមួយដែលផ្អែកលើអនុវិស័យ។

ឧបសគ្គមួយ ដែលរាំងស្ទះកំណើនផលិតភាពវិស័យឯកជន គឺកម្លាំងពលកម្មមានជំនាញមិនគ្រប់គ្រាន់ ឬមិនសមស្រប។ ការផ្តល់ឲ្យជនកម្ពុជានូវជំនាញសមស្រប អាចជួយបង្កើនពិពិធកម្មសេដ្ឋកិច្ច ឲ្យវាលែងមានមូលដ្ឋានតូចចង្អៀត ព្រមទាំងបង្កើតឱកាសការងារក្នុងវិស័យឧស្សាហកម្ម ដូចជា ការកែច្នៃកសិផល កម្មន្តសាលមិនមែនកាត់ដេរ និងក្នុងសេវាកម្មផ្សេងៗ។ វាក៏ជួយបង្កើតឱកាសការងារក្នុងវិស័យឯទៀតៗ ដែលអាចកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន។ កម្លាំងពលកម្មមានជំនាញសមស្រប ក៏ជួយបង្កើនសមត្ថភាពរបស់ឧស្សាហកម្ម និងរដ្ឋាភិបាល ឲ្យអាចឆ្លើយតបបានលឿនចំពោះវិបត្តិផ្សេងៗទៅអនាគតដែរ ហើយជំនាញនេះ អាចដោះស្រាយបានតាមការបណ្តុះបណ្តាលបន្ថែម ឬការផ្តល់ជំនាញមួយថ្មី។

ដើម្បីកសាងកម្លាំងពលកម្មមានជំនាញសមស្រប គោលនយោបាយត្រូវមានលក្ខណៈជាក់ស្តែង ហើយឆ្លើយតបនឹងស្ថានភាពសេដ្ឋកិច្ចពិតៗ។ ការផ្តល់ព័ត៌មានគ្មានប្រសិទ្ធភាព អាចបង្កអប្រសិទ្ធភាពក្នុងទីផ្សារពលកម្ម និងជាឫសគល់នៃភាពមិនស៊ីគ្នា រវាងតម្រូវការ និងជំនាញដែលមានសព្វថ្ងៃ។ នាបច្ចុប្បន្ន គេឃើញមានកង្វះខាតការយល់ដឹងពីទីផ្សារ ក្នុងចំណោមកម្លាំងពលកម្មកម្ពុជា កង្វះព័ត៌មានសម្រាប់យុវជន ឪពុកម្តាយ និងអ្នកស្វែងរកការងារ និងកង្វះយន្តការស្ថាប័នសម្រាប់ធ្វើការសម្របសម្រួលរវាងអ្នកធ្វើគោលនយោបាយ និងថ្នាក់ដឹកនាំអាជីវកម្ម។

គោលនយោបាយ ក៏គួរផ្តោតលើការបំបាត់បញ្ហាទទួលបានព័ត៌មានមិនដូចគ្នាដែរ។ ឧទាហរណ៍ យន្តការសម្រាប់ផ្តល់បានកាន់តែច្រើននូវឱកាសហាត់ការ ឬបម្រើការយកបទពិសោធន៍ជាក់ស្តែង ដូចជា ទស្សនកិច្ចសិក្សា ជាដើម អាចជួយឲ្យពលករវ័យក្មេង បានផ្សាំខ្លួននឹងជំនាញផ្សេងៗ ហើយងាយរកបានការងារធ្វើ។ ការឆ្លើយតបចំពោះការរំពឹងទុក និងការយល់ឃើញរបស់សមាជិកគ្រួសារ ដែលជាអ្នកសម្រេចអារកាត់លើការសិក្សាអប់រំ និងវិនិយោគធនធានក្នុងបញ្ហានេះ ក៏សំខាន់ណាស់ដែរ ព្រោះជួយជៀសវាងការខ្ជះខ្ជាយធនធានគ្រួសារដ៏កម្រទៅលើការសិក្សា ដែលទំនងផ្តល់ប្រាក់ចំណូលតិចទៅអនាគត។

កិច្ចសហប្រតិបត្តិការ រវាងវិស័យឯកជន-សាធារណៈដ៏សកម្ម និងមានប្រសិទ្ធភាព គឺសំខាន់ខ្លាំងណាស់សម្រាប់បង្កើនសមត្ថភាពរបស់កម្ពុជា ក្នុងការអនុវត្តកម្មវិធីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលផ្តល់ឲ្យកម្លាំងពលកម្មនូវជំនាញបច្ចេកទេស និងវិជ្ជាជីវៈដ៏ចាំបាច់ ដើម្បីជួយជំរុញ និងធ្វើពិពិធកម្មសេដ្ឋកិច្ច ហើយក៏ជាស្ពានសម្រាប់ឲ្យពលករវ័យក្មេងរកបានការងារធ្វើ ព្រោះមានជំនាញដែលនិយោជកត្រូវការ។ ដូច្នេះ តម្រូវការរបស់វិស័យឯកជន គួរតែបានគិតបញ្ចូលទៅក្នុងកម្មវិធីសិក្សា TVET ហើយក្របខ័ណ្ឌផ្សេងៗសម្រាប់ជួយសម្រួលកិច្ចសហប្រតិបត្តិការបែបនេះ ក៏គួរបង្កើតឡើងដែរ។ កិច្ចសហការជាដៃគូលើ TVET នេះ អាចផ្តល់ឧត្តមភាពប្រៀបធៀបដ៏ធំមួយឲ្យកម្ពុជានៅក្នុងតំបន់។ ទីតាំងជាយុទ្ធសាស្ត្រនៅចំកណ្តាលអាស៊ាន អាចជួយឲ្យកម្ពុជាទទួលបានមធ្យោបាយបណ្តុះបណ្តាលរបស់អាស៊ាន ដែលមានគុណភាពកម្រិតពិភពលោក បើសិនចេះប្រើប្រាស់បណ្តាញចំណេះដឹងក្នុងតំបន់យ៉ាងសក្តិសិទ្ធិ។

នាបច្ចុប្បន្ន មានកំហិតជាច្រើនដែលកាត់បន្ថយប្រសិទ្ធភាព TVET ដូចជា បញ្ហាថវិកា កង្វះខាតកន្លែងបង្រៀន គ្រូបង្គាត់/អ្នកបណ្តុះបណ្តាលមានគុណភាពល្អមានតិចនាក់ និងកង្វះការសម្របសម្រួលឲ្យមានគ្រូបង្គាត់/អ្នកបណ្តុះបណ្តាល ពីវិស័យឯកជនមកជួយបង្រៀន។ ប៉ុន្តែកំហិតធំបំផុត គឺកង្វះសមត្ថភាពអនុវត្ត TVET តាមបែបបទ និងទំហំមួយដែលអាចដោះស្រាយបានពិតៗ នូវបញ្ហាកង្វះជំនាញក្នុងទីផ្សារពលកម្មកម្ពុជា។ នៅក្នុងស្រទាប់ប្រជាជនក៏មានការយល់ឃើញថា TVET មិនសូវមានមុខមាត់ទេ និងសម្រាប់តែពួកកម្មករ។ ការយល់ឃើញបែបនេះ ត្រូវកែតម្រូវមកវិញ តាមរយៈការឃោសនាផ្សព្វផ្សាយ (សារព័ត៌មាន ទូរទស្សន៍ វិទ្យុ) បទបញ្ញត្តិច្បាប់សមស្រប និងឯកសារបញ្ជាក់គុណភាព។

កម្មវិធីបណ្តុះបណ្តាលលើការងារជាក់ស្តែង ដែលស្របតាមតម្រូវការ និងផ្តល់ឲ្យយុវជននូវជំនាញផ្សេងៗ សម្រាប់ចូល

ប្រឡូកក្នុងទីផ្សារការងារ សព្វថ្ងៃក៏មានខ្លះហើយដែរ ប៉ុន្តែសំខាន់បំផុតគេត្រូវបញ្ជ្រាប និងពង្រីកកម្មវិធី TVET ល្អៗថែមទៀត ព្រមទាំងដាក់អនុវត្តនីតិវិធីផ្សេងៗ ដើម្បីសម្រេចការងារនេះឲ្យបាន។

កម្មវិធី TVET មិនមែនជាឱសថទិព្វសម្រាប់ដោះស្រាយកង្វះជំនាញនៅកម្ពុជានោះទេ៖ រដ្ឋាភិបាល ស្ថាប័នសិក្សាអប់រំ និងវិស័យឯកជន ត្រូវតែប្រឹងប្រែងកែលំអលើគ្រប់ទិដ្ឋភាពនៃប្រព័ន្ធសិក្សាអប់រំ តាំងពីថ្នាក់បឋម ដល់ TVET ដល់ថ្នាក់ឧត្តមសិក្សា ក៏ដូចជាពិនិត្យតាមដានលទ្ធផលការងាររបស់និយោជិត និងធ្វើការបណ្ដុះបណ្ដាលឡើងវិញតាមការចាំបាច់។ ក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយបែបនេះហើយ ដែលជាមធ្យោបាយសម្រាប់ដោះស្រាយ មហិច្ឆតារយៈពេលមធ្យម និងវែងរបស់រដ្ឋាភិបាល។

ដើម្បីសម្រេចបានចីរភាព ការអភិវឌ្ឍវិស័យឯកជន ត្រូវរក្សាតុល្យភាព រវាងកំណើនសេដ្ឋកិច្ច និងបរិស្ថាន។ វិស័យទេសចរណ៍កំពុងផុសឡើង ជាកម្លាំងជំរុញកំណើនដែលមិនបំផ្លិចបំផ្លាញដល់ជម្រកធម្មជាតិផ្សេងៗ។ អាជីវកម្មអេកូទេសចរណ៍មានផលប្រយោជន៍ខាងសេដ្ឋកិច្ច ក្នុងការការពារបរិស្ថានធម្មជាតិ ហើយចំណុចនេះ ជាហេតុផលសំខាន់មួយសម្រាប់ទាក់ទាញភ្ញៀវ។ អាជីវកម្មអេកូទេសចរណ៍ថ្មីៗជាច្រើន កំពុងផុសឡើងនៅពាសពេញប្រទេស ជាពិសេសនៅតាមតំបន់មានអត្ថប្រយោជន៍ខាងវិទ្យាសាស្ត្រ ដូចជា ជួរភ្នំក្រវាញក្នុងខេត្តកោះកុង និងតំបន់ដាច់ស្រយាលក្នុងខេត្ត មណ្ឌលគិរី និងរតនគិរី។ ការកែលំអប្រព័ន្ធផ្លូវតភ្ជាប់ និងដឹកជញ្ជូន ក៏បានជួយឲ្យតំបន់ទេសចរណ៍ទាំងនេះស្ទុះឡើងយ៉ាងលឿនដែរ។ ការអភិវឌ្ឍកោះមួយចំនួននៅខាងត្បូងខេត្តព្រះសីហនុដោយវិស័យឯកជន ក៏បានយកចិត្តទុកដាក់ខ្លាំងដែរ លើការការពារបរិស្ថានធម្មជាតិ។ គំរូធ្វើអាជីវកម្មមានការទទួលខុសត្រូវខ្ពស់ខាងបរិស្ថានបែបនេះ រដ្ឋាភិបាលគួរតែជំរុញឡើង និងផ្ដល់ការលើកទឹកចិត្ត ហើយមជ្ឈដ្ឋានខាងសិក្សាស្រាវជ្រាវ ក៏គួរជួយផ្ដល់ព័ត៌មានឲ្យដែរ។

ឧស្សាហកម្មដទៃទៀត មានផលប៉ះពាល់ជាអវិជ្ជមានច្រើនជាងលើបរិស្ថាន។ សម្បទានដីសេដ្ឋកិច្ច (ELCs) បានក្លាយប្រភពទាក់ទាញវិនិយោគពីបរទេសដ៏មានតម្លៃ សម្រាប់កម្ពុជា។ ផលិតផលបានមកពីសម្បទានទាំងនេះ ជាពិសេសកៅស៊ូ ផ្ដល់ប្រាក់ចំណូលពីការនាំចេញយ៉ាងច្រើនដល់កម្ពុជា។ ក្នុងពេលជាមួយគ្នា ការធ្វើចំការក្នុងសម្បទានដីសេដ្ឋកិច្ច តែងនាំឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលបរិស្ថាន។ សកម្មភាពទាំងនេះ ត្រូវមានការគ្រប់គ្រង និងត្រួតពិនិត្យត្រឹមត្រូវ ដើម្បីធានាថា ផលប៉ះពាល់អវិជ្ជមានលើបរិស្ថានមានតិចតួចបំផុតតាមអាចធ្វើបាន។ ផលប៉ះពាល់មិនល្អលើបរិស្ថាន អាចកាត់បន្ថយបានយ៉ាងច្រើន តាមរយៈការអនុវត្តក្របខ័ណ្ឌសមស្របនានា។

## កំណើនសម្បូរបែប និងសម្រាប់គ្រប់គ្នា

កំណើនសេដ្ឋកិច្ចខ្ពស់ ជាមូលដ្ឋានគ្រឹះ និងជារង្វាស់ចម្បងនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ប្រកបដោយជោគជ័យ។ ដោយមូលហេតុនេះ អ្នកបង្កើតគោលនយោបាយបានប្រឹងប្រែងជាយូរមកហើយ ដើម្បីបង្កើតលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលជួយជំរុញកំណើនលឿន។ ប៉ុន្តែនាពេលបច្ចុប្បន្ន មានការទទួលស្គាល់កាន់តែច្រើនឡើងថា ប្រសិនបើចង់ឲ្យមានកំណើនខ្ពស់ក្នុងរយៈពេលមធ្យម និងវែង ត្រូវមានកិច្ចប្រឹងប្រែងរួមគ្នា ដើម្បីធានាឲ្យកំណើននោះរីកដុះដាលដល់គ្រប់វិស័យ ក្រុមប្រជាជន និងតំបន់ភូមិសាស្ត្រ។ ដូច្នេះ កំណើនសម្រាប់គ្រប់គ្នា វាផ្សារភ្ជាប់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រយ័ត្នប្រយែង ទៅនឹងគោលនយោបាយសង្គម និងមីក្រូសេដ្ឋកិច្ចសកម្មប្រយុទ្ធ ដើម្បីធានាឲ្យកំណើននៅតែមានកម្រិតខ្ពស់ ប៉ុន្តែមាននិន្នាការប្រកបដោយសមធម៌។

តាមគ្រប់សញ្ញាអាចពិនិត្យឃើញ កម្ពុជាបានជឿនលឿនគួរឲ្យកត់សម្គាល់ ក្នុងការកាត់បន្ថយភាពក្រីក្រនៅពីរទសវត្សរ៍ចុងក្រោយនេះ ដោយមានកំណើនសេដ្ឋកិច្ចខ្ពស់ជាច្រើនឆ្នាំ។ ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) បង្ហាញថា អត្រាប្រជាជនក្រីក្រគិតតាមខ្សែបន្ទាត់ភាពក្រីក្រជាតិ បានធ្លាក់ចុះដល់ ៣០,១% នៅឆ្នាំ២០០៧ ធៀបនឹង ៤៧% នៅឆ្នាំ១៩៩៤។ ចំណែកឯទិន្នន័យបានពីអង្កេតជាបន្តបន្ទាប់របស់វិទ្យាស្ថាន CDRI បង្ហាញថា ភាពក្រីក្រធ្លាក់ចុះ ១០ឯកតាភាគរយ ក្នុងចន្លោះឆ្នាំ ២០០១ និង ២០១១។

និន្នាការរួម បានបង្ហាញច្បាស់ពីការធ្លាក់ចុះភាពក្រីក្រ ក៏ពិតមែន ប៉ុន្តែមានកត្តាជាច្រើនទៀតបង្ហាញថា អត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ចនៅកម្ពុជា មិនទាន់បំពេញបានតាមគ្រប់លក្ខណៈវិនិច្ឆ័យនៃកំណើនសម្រាប់គ្រប់គ្នានោះទេ។ ទី១ អត្រាកាត់បន្ថយភាពក្រីក្រ មិនបានដូចគ្នាទាំងអស់នៅក្នុងប្រជាជនទាំងមូលទេ។ ទិន្នន័យរបស់ CDRI បង្ហាញថា យេនឌ័រនៃមេគ្រួសារជាកត្តាដ៏សំខាន់មួយ ដែលជះឥទ្ធិពលលើអត្រាកាត់បន្ថយភាពក្រីក្រ។ នៅចន្លោះឆ្នាំ២០០១ និង ២០១១ ចំនួនគ្រួសារមានបុរសជាមេគ្រួដែលក្រីក្រ បានធ្លាក់ចុះ ១១,៨% រីឯចំនួនគ្រួសារមានស្ត្រីជាមេគ្រួដែលក្រីក្រ បានធ្លាក់ចុះត្រឹមតែ ៥,៥% ប៉ុណ្ណោះ។ ទិន្នន័យ CSES បង្ហាញពីភាពខុសគ្នារវាងប្រជាជនរស់នៅទីក្រុង និងជនបទ៖ នៅចន្លោះឆ្នាំ២០០៤ និង ២០០៧ ចំនួនគ្រួសារក្រីក្ររស់នៅជនបទ បានធ្លាក់ចុះ ១១,១% ហើយចំនួនគ្រួសារក្រីក្ររស់នៅទីក្រុង បានធ្លាក់ចុះ ១៣,៣%។ ប្រសិនបើនិន្នាការបច្ចុប្បន្នមិនប្រែប្រួល វិសមភាពរវាងតំបន់ជនបទនិងទីក្រុង និង រវាងគ្រួសារមានស្ត្រីជាមេគ្រួនិងមានបុរសជាមេគ្រួ នឹងកើនឡើងនៅពេលអនាគត។

ទី២ ទាក់ទិននឹងកំណើនសម្រាប់គ្រប់គ្នា ក្រៅពីការវាស់វែងតាមប្រាក់ចំណូលនេះ ប្រទេសកម្ពុជាសម្រេចបានលទ្ធផលមិនល្អទេ។ តារាង ១ បង្ហាញថា សន្ទស្សន៍កំណើនសម្រាប់គ្រប់គ្នារបស់កម្ពុជា មានកម្រិត "ល្អបង្គួរ" ក៏ពិតមែន ប៉ុន្តែវាផ្អែកលើការកាត់បន្ថយភាពក្រីក្រ ដែលជំរុញឡើងដោយអត្រា "ល្អប្រសើរ" នៃកំណើនសេដ្ឋកិច្ច និងអត្រាសឹងតែ "ល្អប្រសើរ" នៃចំណាយប្រើប្រាស់។ ប៉ុន្តែកត្តាផ្សេងទៀតដែលរួមចំណែកបង្កើតបរិយាកាសអំណោយផល ដូចជា កិច្ចការពារខាង

តារាង ១៖ សន្ទស្សន៍កំណើនសម្រាប់គ្រប់គ្នានៅប្រទេសកម្ពុជា

| | ពិន្ទុ | ទម្ងន់ | សរុប |
|---|---|---|---|
| 1. កំណើន | 8 | 0.25 | 2.00 |
| 2. ភាពមានការងារធ្វើ | 4 | 0.15 | 0.60 |
| 3. ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច | 4 | 0.10 | 0.40 |
| 4. ភាពក្រីក្រ | 6 | 0.10 | 0.60 |
| 5. វិសមភាព | 4 | 0.10 | 0.40 |
| 6. សមធម៌យេនឌ័រ | 6 | 0.05 | 0.30 |
| 7. សុខភាព និងអាហារូបត្ថម្ភ | 3 | 0.05 | 0.15 |
| 8. ការអប់រំ | 4 | 0.05 | 0.20 |
| 9. អនាម័យ និងទឹក | 4 | 0.05 | 0.20 |
| 10. កិច្ចការពារខាងសង្គមកិច្ច | 2 | 0.10 | 0.20 |
| សរុប | | 1.00 | *5.05* |

*សំគាល់៖ ១-៣=លទ្ធផលមិនល្អ ៤-៧=លទ្ធផលល្អបង្គួរ ៨-១០=លទ្ធផលល្អប្រសើរ*

*ប្រភព៖ Mckinleg (២០១០) ដកស្រង់ពីក្នុងបទបង្ហាញរបស់បណ្ឌិត គុង គឹមស៊ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា នៅថ្ងៃទី១៦ កុម្ភៈ ២០១២*

សង្គមកិច្ចសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ជាដើម នៅខ្វះខាតខ្លាំងណាស់។

ដើម្បីសម្រេចបានកំណើនសម្រាប់គ្រប់គ្នា អ្នកបង្កើតគោលនយោបាយ ត្រូវអនុវត្តវិធីសាស្ត្របីមុខព្រួញ ដែលតភ្ជាប់ម៉ាក្រូសេដ្ឋកិច្ច មីក្រូសេដ្ឋកិច្ច និងគោលនយោបាយសង្គម ហើយគោលនយោបាយនានា ត្រូវអនុវត្តតាមរយៈក្របខ័ណ្ឌស្ថាប័នដែលមានអភិបាលកិច្ចល្អ និងតម្លាភាព។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាកំណើន ផសស ជាប់លាប់ គឺជាកត្តាសំខាន់បំផុតដែលជំរុញកំណើនសម្រាប់គ្រប់គ្នា តាមរយៈការបង្កើតការងារ។ ដូច្នេះជាការសំខាន់ណាស់ ដែលរដ្ឋាភិបាលត្រូវរក្សាឲ្យមានស្ថិរភាពនៅពេលអនាគត ជាពិសេសអត្រាអតិផរណាអាចគ្រប់គ្រងបាន (នៅក្រោម ៥% ជាការប្រសើរ)។ ប្រហែល ៩០% នៃគ្រួសារក្រីក្រ ពឹងផ្អែកលើការរកចិញ្ចឹមជីវិតនៅទីជនបទ ដូច្នេះ រដ្ឋាភិបាលត្រូវប្រឹងប្រែងទ្វេឡើងទៀតក្នុងការរៀបចំថ្លឹងថ្លែងសេដ្ឋកិច្ចឡើងវិញ ដើម្បីឲ្យសមស្របតាមធាតុពិតនេះ។

ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ជាកត្តាចាំបាច់បំផុត ប្រសិនបើចង់ឲ្យកំណើន ជ្រាបចូលទៅដល់តំបន់ភូមិសាស្ត្រដាច់ស្រយាល និងគ្រប់វិស័យ។ តំបន់ជាយៗ ជាកន្លែងប្រមូលផ្តុំភាពក្រីក្រ ដូច្នេះ ការបើកចំហតំបន់ទាំងនេះទៅកាន់ទីផ្សារនានា តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាកត្តាសំខាន់បំផុត។ កម្មវិធីគ្របដណ្តប់រួម ADB-GMS បានដើរតួនាទីស្នូលក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធនៅតាមច្រករបៀងសេដ្ឋកិច្ចសំខាន់ៗ ហើយវាបានតភ្ជាប់តំបន់ជាយៗរបស់ប្រទេសកម្ពុជា ទៅនឹងទីផ្សារជាតិ ទីផ្សារក្នុងតំបន់ និងលើពិភពលោក។ ការផ្តល់សេវាកម្មជួយបំពេញបន្ថែម ក៏ត្រូវមានដែរ ដើម្បីបង្កើនផលិតភាព ជាពិសេសក្នុងចំណោមប្រជាជនភាគច្រើនដែលរស់នៅជនបទ ក្នុងនោះមានជាច្រើននាក់កំពុងធ្វើកសិកម្មលើដីតូចៗ។

កង្វះខាតប្រព័ន្ធផ្តល់ឥណទានផ្លូវការ នៅតែជាឧបសគ្គចម្បងមួយចំពោះកសិករ និងអាជីវករសហគ្រាសខ្នាតតូច និងមធ្យម ទោះបីក្នុងវិស័យនេះ មានរីកចម្រើនច្រើនហើយក្តី។ វិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា បានដើរតួនាទីឈានមុខក្នុងការពង្រីកសេវាកម្មហិរញ្ញវត្ថុផ្លូវការ ទៅដល់ប្រជាជនក្រីក្រនៅជនបទ។ ក្នុងប្រាំឆ្នាំចុងក្រោយ វិស័យនេះរីកលូតលាស់យ៉ាងលឿន ដោយមានអ្នកខ្ចីប្រាក់ដល់ទៅ ១,៣លាននាក់ និងអ្នកសន្សំប្រាក់ ១,១លាននាក់ ក្នុង ២៤ខេត្តក្រុង។ ប្រាក់បញ្ញើកើន ៣២% ដល់១,២៦ពាន់លានដុល្លារ នៅឆ្នាំ២០១១ ធៀបនឹង ៩៥២លានដុល្លារ នៅឆ្នាំ២០១០។ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ បានរីកលូតលាស់ទៅមុខ ជាអាទិ៍គម្រោងធារាសាស្ត្រភាគពាយ្យសាន ទទួលមូលនិធិពី ADB ដែលមាន ១២អនុគម្រោង សម្រាប់ផ្តល់ប្រព័ន្ធធារាសាស្ត្រ ខ្នាតតូច និងមធ្យម និងសំណង់គ្រប់គ្រងទឹកកាន់តែមានប្រសិទ្ធភាព ក្នុងការផ្តល់ទឹកស្រោចស្រពបន្ថែមនៅរដូវវស្សា ដល់ដីស្រែ និងចំការប្រមាណ ១១.០០០ហិកតា។

ចាំបាច់ត្រូវមានគោលនយោបាយដោះស្រាយ បញ្ហាក្រឹត្យក្រមខាងសង្គម និងវប្បធម៌ដែលរារាំងស្ត្រីមិនឲ្យទទួលបានឱកាសសេដ្ឋកិច្ច ដូចជា ការងារ ឥណទាន និងសេវាកម្មផ្សេងៗ។ ចំណែកដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រនារីរតនៈ III របស់

ក្រសួងកិច្ចការនារី គឺការកសាងគោលនយោបាយកម្រិតជាតិ ដើម្បីលើកកម្ពស់សមធម៌យេនឌ័រ នៅក្នុងឱកាសសេដ្ឋកិច្ច។ កម្មវិធីនេះ សំដៅញាំងឲ្យមានការផ្លាស់ប្ដូរជាក់ស្ដែងក្នុងគំរូយេនឌ័រផ្នែកវប្បធម៌ ដែលលំអៀងទៅគាំទ្រការចូលរួមរបស់បុរសក្នុងសកម្មភាពសេដ្ឋកិច្ចមួយចំនួន ដូចជា ការទិញ ឬបន្តមរតកជាដើម តាមការជំរុញគោលនយោបាយដែលបំបាត់របាំងរារាំងស្ត្រីក្នុងការចូលរួមក្នុងគ្រប់វិស័យសេដ្ឋកិច្ច។

សម្រាប់គោលនយោបាយសង្គមវិញ កម្ពុជានៅយឺតយ៉ាវជាខ្លាំង ជាងប្រទេសឯទៀតក្នុងតំបន់ ក្នុងការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ និងប្រព័ន្ធការពារខាងសង្គមកិច្ច។ កង្វះប្រព័ន្ធការពារខាងសង្គមកិច្ច និងសេវាថែទាំសុខភាព ប៉ះពាល់ជាអវិជ្ជមានទៅលើអត្រាកំណើន និងរួមចំណែកបង្កនិន្នាការកំណើនដែលមិនមែនសម្រាប់គ្រប់គ្នា៖ គ្រួសារក្រីក្រដែលនៅតែតស៊ូតតឈប់ឈរ ដើម្បីគ្រាន់តែដោះស្រាយតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់ខ្លួននោះ កម្រមានផលិតភាពណាស់ ព្រោះពួកគេរវល់តែរកឲ្យបានមួយរស់ៗ ហើយត្រូវជាប់ផុងក្នុងភាពក្រីក្រដដែល។

នៅកម្ពុជានាបច្ចុប្បន្ន មិនទាន់មានប្រព័ន្ធការពារខាងសង្គមកិច្ចដ៏ធំទូលាយមួយគ្រប់គ្រងដោយរដ្ឋនោះទេ ប៉ុន្តែគេឃើញមានកិច្ចប្រឹងប្រែងជាច្រើនពីសំណាក់សង្គមស៊ីវិល ក្នុងការផ្ដល់នូវយន្តការគាំទ្រសង្គមសម្រាប់ជនងាយរងគ្រោះបំផុត និងការទ្រទ្រង់ដល់គម្រោងជាក់លាក់នានា ដោយដៃគូអភិវឌ្ឍន៍។ ការពឹងផ្អែកលើដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ធ្វើឲ្យការរីកចម្រើនក្នុងវិស័យនេះពុំមានចីរភាពទេ ហើយភាគច្រើនត្រូវដើរតាមរបៀបវារៈរបស់អង្គការខុសៗគ្នាជាច្រើន។

នាពេលថ្មីៗនេះ រដ្ឋាភិបាលបានបង្កើតយុទ្ធសាស្ត្រជាតិការពារសង្គម (NSPS) ឆ្នាំ២០១១-១៥ ដែលកាន់តែគ្រប់ជ្រុងជ្រោយឡើង ដើម្បីដោះស្រាយបញ្ហាខ្វះខាតប្រព័ន្ធការពារខាងសង្គមកិច្ចនៅកម្ពុជា។ ក្របខ័ណ្ឌ NSPS បានកាត់តម្រឹមកម្មវិធីខាងសង្គមកិច្ចដែលមានស្រាប់ទាំងឡាយ ដោយផ្អែកលើក្របខ័ណ្ឌធំទូលាយជាងមុនមួយ ដែលនឹងការពារជនក្រីក្រ និងជនងាយរងគ្រោះ ជាពិសេស គ្រួសារមានស្ត្រីជាមេគ្រួសារ ព្រមទាំងជួយសម្រួលឲ្យពួកគេបានចូលរួម ក្នុងសកម្មភាពសេដ្ឋកិច្ចមានផលិតភាព។ ក្របខ័ណ្ឌនេះ រួមមាន ប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងប្រព័ន្ធផ្សេងៗទៀត សម្រាប់កែលំអអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ និងលើកកម្ពស់ការអប់រំ។ រដ្ឋាភិបាល គួរប្រឹងប្រែងធ្វើយ៉ាងណាឲ្យកំណែទម្រង់ទាំងនេះ អនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព។

## សន្និដ្ឋាន៖ ការកែតម្រូវភាពមិនស៊ីគ្នារវាងគោលនយោបាយ និងស្ថាប័ន

សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ជាបញ្ហាចោទធំបំផុតចំពោះកម្ពុជា ក្នុងការសម្រេចបានកំណើនសម្បូរបែប មានចីរភាព និងសម្រាប់គ្រប់គ្នា។ រដ្ឋាភិបាល បានបង្កើត និងដាក់អនុវត្តនូវក្របខ័ណ្ឌគោលនយោបាយផ្ដួចផ្ដើមថ្មីជាច្រើន ដែលបានដំណើរការយ៉ាងល្អ ឈានទៅសម្រេចបានគោលដៅនៃកំណើនមានចីរភាព ប៉ុន្តែបញ្ហាចោទ គឺការអនុវត្តគោលនយោបាយទាំងនោះ។

ភាពមិនស៊ីគ្នា រវាងស្ថាប័ន និងគោលនយោបាយ អាចរាំងស្ទះដល់ការអភិវឌ្ឍសម្រាប់គ្រប់គ្នា ហើយចំណុចនេះអាចមើលឃើញច្បាស់បំផុតក្នុងបញ្ហាដីធ្លី។ ដីធ្លីសំខាន់ខ្លាំងណាស់សម្រាប់គ្រួសារក្រីក្រ ព្រោះអាចគួបផ្សំជាមួយកម្លាំងពលកម្ម (សម្បត្តិចម្បងរបស់គ្រួសារក្រីក្រ) ដើម្បីបង្កើតប្រាក់ចំណូល។ ដូច្នេះ សិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព គឺជាលក្ខខណ្ឌដ៏ចាំបាច់នៃកំណើនសម្រាប់គ្រប់គ្នា។ ក្របខ័ណ្ឌគោលនយោបាយបានទទួលស្គាល់កម្មសិទ្ធិស្របច្បាប់លើដីធ្លីក៏ពិតមែន ប៉ុន្តែស្ថាប័នសម្រាប់ពង្រឹងអនុវត្តច្បាប់ មិនបានរីកលូតលាស់លឿនដូចច្បាប់ទេ។ ជាលទ្ធផល មានទំនាស់ដីធ្លីកើតឡើងច្រើនណាស់ និងមានករណីរឿងក្ដីនៅច្រើនកកកុញ នៅឯគណៈកម្មាធិការសុរិយោដី ធ្វើឲ្យប្រជាជនបាត់បង់ទំនុកចិត្តលើសុវត្ថិភាពកាន់កាប់ដីធ្លី និងថមថយការរួមចំណែកក្នុងសេដ្ឋកិច្ច។ ចំណុចខ្វែងគំនិតគ្នាធំមួយ គឺការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច (ELCs)។ ក្នុងការងារនេះ ក៏មានគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់បែងចែក និងពិនិត្យតាមដាន ELCs ដែរ ប៉ុន្តែក្នុងករណីខ្លះ ក្របខ័ណ្ឌទាំងនេះមិនត្រូវបានអនុវត្តតាមទេ ធ្វើឲ្យការប្រើប្រាស់ដីពុំមានប្រសិទ្ធភាពគ្រប់គ្រាន់ ហើយបង្កឧបសគ្គដល់ការចូលរួមក្នុងសកម្មភាពបង្កើតមូលធនរបស់គ្រួសារនៅតាមមូលដ្ឋាន។

កំណែទម្រង់ស្ថាប័នមូលដ្ឋាន ដែលដើរតួនាទីគន្លឹះក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារនានា ក៏សំខាន់ណាស់ដែរ សម្រាប់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច ប្រកបដោយសមធម៌។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល បានធ្វើការកែទម្រង់ក្រុមប្រឹក្សាឃុំឲ្យកាន់តែមានសមធម៌ ប្រសិទ្ធភាព និងតម្លាភាព ក្នុងការផ្ដល់សេវាកម្ម និងគ្រប់គ្រងប្រជាជនមូលដ្ឋាន។

ក្នុងមួយទសវត្សរ៍កន្លងទៅ កម្ពុជាសម្រេចលទ្ធផលបានច្រើនហើយ ក្នុងការពង្រឹងស្ថាប័នរបស់ប្រទេស ប៉ុន្តែនៅមានការងារត្រូវអនុវត្តជាច្រើនទៀត។ ឆ្នាំ២០១២ ផ្ដល់នូវឱកាសល្អណាស់ ដើម្បីឲ្យកម្ពុជាសម្រេចបានស្ថិរភាព សមភាព និងការរីកចម្រើន ប៉ុន្តែឧបសគ្គខាងសមត្ថភាពស្ថាប័ន ក៏នៅតែឃើញមាន។ ដូច្នេះ ជាការចាំបាច់ណាស់ដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវបន្តផ្ដល់អាទិភាព ចំពោះបញ្ហានេះ និងសម្របសម្រួលធនធានដើម្បីលុបបំបាត់ឧបសគ្គចម្បងមួយនេះ។ នៅពេលដោះស្រាយបញ្ហានេះបានហើយ កម្ពុជារំពឹងថា នឹងអាចទទួលអត្ថប្រយោជន៍ពីចំណងទាក់ទង ផ្នែកសេដ្ឋកិច្ចខ្លាំងក្លាជាមួយដៃគូក្នុងតំបន់ និងមកពីតំបន់ដទៃទៀត ព្រមទាំងអាចជំរុញនិន្នាការកំណើនមួយដ៏សម្បូរបែប ស្មើភាព និងប្រកបដោយចីរភាព។